គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

បំរើ ការពារ កសាង

កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ

ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍ ថ្ងៃសុក្រ ទី១៧ ខែមេសា ឆ្នាំ២០០៩ ព្រឹត្តិប័ត្រលេខ៨០ ឆ្នាំទី២


| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -ប៉ូលីសចរាចរកាក់កបនៅដើមឆ្នាំ២០០៩ | ១ |
| -ស្ថានភាពសិទ្ធិមនុស្សកម្ពុជានៅដើមឆ្នាំ២០០៩មានសភាពធ្ងន់ធ្ងរជាងដើមឆ្នាំ២០០៨ | ២ |
| -សកម្មជនគណបក្សសិទ្ធិមនុស្សត្រូវបានជនមិនស្គាល់មិនសម្លាប់ | ២ |
| -អាជ្ញាធរនៅតែមានការរើសអើងនិងប្រកាន់និន្នាការនយោបាយ | ៣ |
| -នាយករដ្ឋមន្ត្រីព្រមានដល់ប្រជាពលរដ្ឋណាដែលទទួលការជួយពីគណបក្សប្រឆាំង | ៤ |


## ប៉ូលីសចរាចរកាក់កបនៅដើមឆ្នាំ២០០៩

អ្នកធ្វើដំណើរនៅក្រុងភ្នំពេញបាននិយាយថា ប៉ូលីសចរាចរ ដែលឈរជើងនៅតាមចំណុចភ្លើងស្តុបនានានៅទីក្រុងភ្នំពេញ ជាពិសេសនៅគល់ស្ពានស្ទឹងមានជ័យ កំពុងប្រកបរបរយ៉ាងកាក់កប ក្នុងការជំរិតទារលុយពីសំណាក់ប្រជាពលរដ្ឋដែលធ្វើដំណើរនៅតាម ផ្លូវសាធារណៈខណៈដែលយានជំនិះរបស់ពួកគាត់មិនមានស្លាកលេខមិនដាក់កញ្ចក់ ឬក៏មិនពាក់មួកដើម្បីការពារសុវត្ថិភាព ។

ប្រជាពលរដ្ឋបានលើកឡើងទៀតថា បើទោះជាម៉ូតូមានស្លាកលេខ ដាក់កញ្ចក់ហើយអ្នកជិះពាក់មួកសុវត្ថិភាពត្រឹមត្រូវហើយក្តី បើអ្នកនោះមកពីស្រែចំការក៏ប៉ូលីសចរាចរឃាត់ទារលុយផងដែរ ។

អ្នកជិះម៉ូតូម្នាក់នៅក្រុងភ្នំពេញ បានប្រាប់ក្នុងលក្ខខណ្ឌមិនបញ្ចេញឈ្មោះថា គាត់បានឃើញប៉ូលីសនៅគល់ស្ពានស្ទឹងមានជ័យ តែងតែយកលុយពីប្រជាពលរដ្ឋហើយ មិនចេញបង្កាន់ដៃឱ្យពួកគេទាំងនោះទេ ។ មិនតែប៉ុណ្ណោះក្រុមប៉ូលីសទាំងនោះបានស្លៀកពាក់ស៊ីវិលចាំយកលុយពីរថយន្តឈ្នួល ឬរថយន្តដឹកតវ៉ាន់ ដែលទង្វើរបែបនេះត្រូវបានគេរិះគន់ថា ជាឆាកល្ខោនរបស់ប៉ូលីសចរាចរក្នុងការជំរិតទារលុយពីប្រជាពលរដ្ឋ ។

យើងមិនអាចសុំការបកស្រាយពីលោក **ទីន ប្រសើរ** ប្រធានការិយាល័យប៉ូលីសចរាចរផ្លូវគោកបានទេ ដោយសារលោករវល់ចូលរួមមីទ្ទីង ។

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្សមានប្រសាសន៍ថា បាតុភាពយកលុយបានកើតឡើងនៅគ្រប់ច្រកល្ហកក្នុងរាជធានីភ្នំពេញ ដោយសារប្រទេសយើងមិនគោរពច្បាប់ ។ លោកក៏បានឃើញប៉ូលីស

ចរាចរទារលុយពីប្រជាពលរដ្ឋរៀងរាល់ថ្ងៃ ដែលយ៉ាងហោចណាស់មួយថ្ងៃលោកឃើញម្តង ឬ២ដងក៏មាន ។

សូមជំរាបថា ចាប់តាំងពីច្បាប់ចរាចរផ្លូវគោកចូលជាធរមាននៅដើមខែមករា ឆ្នាំ២០០៩ ដោយតំរូវឱ្យមានការផាកពិន័យចំពោះអ្នកបើកបរទោចក្រយាន្តយន្ត និងការអំពាវនាវពីសំណាក់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ឱ្យប្រជាពលរដ្ឋខ្មែរពាក់មួកសុវត្ថិភាពផងនោះប៉ូលីសចរាចរ ហាក់មានដើមទុនក្នុងការធ្វើអាជីវកម្មយកលុយកាក់ពីប្រជាពលរដ្ឋ ។

## ស្ថានភាពសិទ្ធិមនុស្សកម្ពុជានៅដើមឆ្នាំ២០០៩មានសភាពធ្ងន់ធ្ងរជាងដើមឆ្នាំ២០០៨

លោក **សំ អាត** មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់នៃអង្គការលីកាដូបានបញ្ជាក់បន្ថែមថា ស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជាយើងបើធៀបទៅនឹងឆ្នាំមុនឃើញថា នៅតែមានសភាពធ្ងន់ធ្ងរដូចជា វប្បធម៌និទណ្ឌភាពនៃការរួចទោសពៃរ៍ ការបាញ់បោះបណ្តាលឱ្យមនុស្សស្លាប់ និងរងរបួសហើយអ្នកបង្កហេតុទាំងនោះមិនត្រូវបានអាជ្ញាធរចាប់ផ្តន្ទាទោសនោះទេ ពិសេសកងកំលាំងប្រដាប់អាវុធ ។

លោក **សំ អាត** បន្តថាមានការចាប់ឃុំឃាំងប្រជាពលរដ្ឋក្នុងជម្លោះដីធ្លី និងការបាញ់ប្រហារប្រជាពលរដ្ឋរហូតមកដល់ពេលនេះមិនទាន់មានវិធានការណាមួយដើម្បីទប់ស្កាត់ និងជួយដល់ជនរងគ្រោះនៅឡើយទេពីសំណាក់រាជរដ្ឋាភិបាល ។ លោកចង្អុលបង្ហាញទៀតថាត្រីមាសទី១ ឬទី៣ដំបូងនៃដើមឆ្នាំ២០០៩តាមអ្វីដែលអង្គការលីកាដូឱ្យដឹងអំពី ករណីរំលោភសិទ្ធិមនុស្សឃើញថា មានការកើនឡើងនេះបើធៀបនឹងត្រីមាសទីមួយនៅឆ្នាំ២០០៨កន្លងទៅ ។ ករណីទំនាស់ដីធ្លីមានការកើនឡើងនិងមានការបាញ់បោះឱ្យរបួសដល់ប្រជាពលរដ្ឋជាហូរហែផងដែរ ។

លោក **នី ចរិយា** ប្រធានផ្នែកស៊ើបអង្កេតនៃសមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជាបានកត់សំគាល់ឃើញថា ការសំលាប់មនុស្សដោយហ្វូងមហាជនមានការថយចុះ និងការគំរាមកំហែងសកម្មជនគណបក្សនយោបាយព្រមទាំងការសំលាប់មានការថយចុះ បើធៀបនឹងអាណត្តិបោះឆ្នោតមុនៗ ។ ប៉ុន្តែស្ថានភាពអាក្រក់នោះគឺការចាប់ឃុំខ្លួនដោយប្រើប្រាស់ប្រព័ន្ធតុលាការសំលាប់ចាប់ឃុំតំណាងប្រជាពលរដ្ឋ ។

លោក **នី ចរិយា** បានគូសបញ្ជាក់ទៀតថា សិទ្ធិបញ្ចេញមតិមានការរឹតត្បិតជាងមុន វិទ្យុជាតិ ទូរទស្សន៍ជាតិមានការរឹតត្បឹតយ៉ាងខ្លាំង សូម្បីតែសង្គមស៊ីវិលក៏ពិបាកក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មានស្តីពីគោលការសិទ្ធិមនុស្សនោះដែរ ។

## សកម្មជនគណបក្សសិទ្ធិមនុស្សត្រូវបានជនមិនស្គាល់មុខសំលាប់

ករណីសំលាប់សកម្មជនគណបក្សសិទ្ធិមនុស្ស លោក **ស៊ីម ណេត** នៅភូមិគោករវៀង ឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក ខេត្តកំពង់ចាមកាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ រហូតមកដល់ថ្ងៃនេះ សមត្ថកិច្ចប៉ូលិសនៅមិនទាន់ចាប់ជនដៃដល់មកផ្តន្ទាទោសតាមច្បាប់នៅឡើយទេ ។

លោក **ស៊ីម យ៉ាន** ប្អូនប្រុសបង្កើតលោក **ស៊ីម ណេត** ត្រូវបានឃាតករសំលាប់កាលពីចុងខែមីនានោះ បានបញ្ជាក់ថាឃាតករបាញ់សំលាប់បងប្រុសរបស់លោកមិននៅឆ្ងាយទេ គឺនៅស្រុកជិតស្រុករបស់លោក ។ ចំណែកអាជ្ញាធរព្រងើយកន្តើយក្នុងការស៊ើបអង្កេតករណីឃាតកម្មមួយនេះ ។ លោកបន្តថាការស្លាប់បងប្រុសរបស់លោកគឺជារឿង នយោបាយពីព្រោះលោក **ស៊ីម ណេត** ជាសកម្មជនគណបក្សសិទ្ធិមនុស្ស ។

លោក **អ៊ី ទី** មេប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំកណ្តោលជ្រុំស្រុកពញាក្រែកមិនឆ្លើយបំភ្លឺចំពោះករណីនេះទេ ដោយលោក

ឱ្យទាក់ទងលោក **ប្រាក់ ហ៊ុន** អធិការស្រុកពញាក្រែកទៅវិញ ។ ចំណែកលោក **ប្រាក់ ហ៊ុន** អធិការស្រុកពញាក្រែកក៏មិនបានឆ្លើយបំភ្លឺផងដែរ លោកគ្រាន់តែបញ្ជាក់ថា ឱ្យមកជួបលោកនៅកន្លែងអធិការដ្ឋាន ។

លោក **នាង សុវ៉ាត** អ្នកសរបសំរួលនៃសមាគមអាដហុកនៅខេត្តកំពង់ចាមបានបញ្ជាក់ថា អាជ្ញាធរគួរតែខិតខំធ្វើការស្វះស្វែងរកមុខសញ្ញា ដែរនេះគឺជាកាតព្វកិច្ចរបស់អាជ្ញាធរ ហើយមិនគួរធ្វើការរើសអើងនិន្នាការនយោបាយគណបក្សណាមួយឡើយ ។ លោកបន្តថា ករណីបាញ់សំលាប់សកម្មជនគណបក្សនយោបាយនៅខេត្តកំពង់ចាម នាត្រីមាសដើមឆ្នាំ២០០៩នេះ មានពីរនាក់គឺសកម្មជនគណបក្សសមរង្ស៊ី នៅស្រុកមេមត់ និងសកម្មជនគណបក្សសិទ្ធិមនុស្សនៅស្រុកពញាក្រែក ដែលការសំលាប់សកម្មជនគណបក្សនយោបាយ គឺធ្វើឱ្យប៉ះពាល់ដល់សិទ្ធិធ្វើនយោបាយរបស់ប្រជាពលរដ្ឋ ។

## អាជ្ញាធរនៅតែមានការរើសអើង និងប្រកាន់និន្នាការនយោបាយ

អាជ្ញាធរភូមិម្កាក់ និងឃុំចំប៉ីក្នុងស្រុកបាទីខេត្តតាកែវ បានរារាំងមិនឱ្យប្រជាពលរដ្ឋ និងសកម្មជនគណបក្សសិទ្ធិមនុស្សរៀបចំពិធីបុណ្យសម្ពោធលូទឹក ស្ថិតនៅភូមិម្កាក់នោះទេកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩នេះ ។

សកម្មជាន់ខ្ពស់របស់គណបក្សសិទ្ធិមនុស្សនៅស្រុកបាទីរៀបរាប់ថាប្រជាពលរដ្ឋ និងអ្នកស្រលាញ់គាំទ្រគណបក្សសិទ្ធិមនុស្សនៅក្នុងភូមិម្កាក់ បានរួមសហការគ្នាដើម្បីកសាងលូទឹកមួយក្រោយពីកសាងរួចហើយនោះអ្នកភូមិ បានរៀបចំពិធីបុណ្យដារឆ្លងលូទឹកនៅក្នុងភូមិ ។ ទន្ទឹមនឹងពិធីបុណ្យនេះអ្នកភូមិបានអញ្ជើញថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សលោក **កឹម សុខា** ឱ្យចូលរួមក្នុងពិធីបុណ្យនេះផងដែរ ។ ប៉ុន្តែអាជ្ញាធរភូមិម្កាក់ហាមឃាត់ដោយមិនអនុញ្ញាតឱ្យថ្នាក់ដឹកនាំសំណេះសំណាល ឬលើកបញ្ហាលូទឹកមកជំរាបប្រជាពលរដ្ឋនោះទេ ។

លោកបន្តថា អាជ្ញាធរភូមិឃុំ មិនបានធ្វើលូទឹកនោះទេ ស្រាប់តែប្រជាពលរដ្ឋអ្នកគាំទ្រគណបក្សសិទ្ធិមនុស្ស រួមគ្នាធ្វើ អាជ្ញាធរភូមិឃុំមករារាំងទៅវិញ ។ អាជ្ញាធរនៅក្នុងស្រុកបាទីមានភាពរើសអើងប្រជាពលរដ្ឋអ្នកភូមិម្នាក់នៅភូមិម្កាក់ ក្នុងឃុំចំប៉ីនេះណាស់ ហើយពួកគាត់បានថ្លែងថាគាត់បានទៅសុំច្បាប់ធ្វើបុណ្យឆ្លងនេះដល់សាលាឃុំចំប៉ី ប៉ុន្តែដោយសារពិធីបុណ្យនោះតំរូវឱ្យលោក **កឹម សុខា** ចូលរួមផងនោះអាជ្ញាធរឃុំបែរជាមិនឱ្យដោយយកលេសថា ព្រែកនោះជារបស់គណបក្សប្រជាជនកម្ពុជា ប៉ុន្តែតាមពិតព្រែកនោះត្រូវបានកសាងដោយសម្តេចឪនរោត្តមសីហនុ ។

គណៈកម្មការសាងសង់លូទឹកបានបញ្ជាក់ថា អ្នកគាំទ្រ និងប្រជាពលរដ្ឋចូលរួមកសាងលូទឹកមានភូមិម្កាក់ ភូមិដើមដូង និងភូមិក្រគៀត បានចំនាយទឹកប្រាក់អស់ចំនួន ៧៥៥ដុល្លារ ។ ថវិការទាំងនោះបានមកពីប្រជាពលរដ្ឋ និងព្រះសង្ឃនៅវត្តដីក្រហមផងដែរ ។

ទាក់ទងទៅនឹងអាជ្ញាធររារាំងអ្នកភូមិមិនឱ្យរៀបចំពិធីបុណ្យសម្ពោធលូទឹក ត្រូវបានគណៈកម្មករកសាងលូទឹកគូសបញ្ជាក់ទៀតថា អាជ្ញាធរភូមិឃុំរារាំងមិនឱ្យពួកគាត់សម្ពោធលូទឹកវាជារឿងល្អទៅវិញទេ ពីព្រោះធ្វើឱ្យប្រជាពលរដ្ឋដឹងថាអ្នកណាល្អអ្នកណាអាក្រក់ ។

លោក **សុង** មេភូមិម្កាក់បានថាប្រជាពលរដ្ឋបានរៀបចំពិធីបុណ្យ មុនបុណ្យចូលឆ្នាំថ្មីរួមផ្សំនឹងឆ្លងសន្ទះទឹកដែលរួមគ្នាកសាងដោយប្រជាពលរដ្ឋបានសហការគ្នាធ្វើ ។

ចំណែកលោក **កឹម សុខា** ក៏បានចូលរួមពិធីបុណ្យនេះដែរ ប៉ុន្តែលោកមិនបាននិយាយអ្វីទាក់ទងនឹងនយោបាយនោះទេ ។

លោកមេភូមិបានបន្តថា ប្រសិនបើលោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស ចូលរួមសម្ពោធសន្ទះទឹក ឬទ្វារទឹកនោះលោកមិនអនុញ្ញាតទេ ។ លោកមេភូមិម្នាក់មិនមានហេតុផលសមស្របណាមួយឆ្លើយតបទៅនឹងសំណួរ ដែលសួរថា ហេតុអ្វីបានជាមិនឱ្យថ្នាក់ដឹកនាំរបស់គណបក្សសិទ្ធិមនុស្សចូលរួមសម្ពោធលូទឹក ។

សូមជម្រាបថា លូទឹកដែលកសាងឡើងដោយប្រជាពលរដ្ឋ និងអ្នកគាំទ្រគណបក្សសិទ្ធិមនុស្សឃុំចំប៉ី គឺលូទឹកនោះមានសារៈប្រយោជន៍សំរាប់ស្តុកទឹកទុក ប្រើប្រាស់នៅរដូវប្រាំង ហើយក៏អាចស្រោចស្រពដល់ផលដំណាំនៅភូមិម្នាក់ និងវត្តដីក្រហមផងដែរ ។

## នាយករដ្ឋមន្ត្រីព្រមានដល់ប្រជាពលរដ្ឋណាដែលទទួលការជួយពីគណបក្សប្រឆាំង

លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានមានប្រសាសន៍ម្តងហើយម្តងទៀត បន្ទាប់ពីលោកថ្លែង នៅក្នុងពិធីសម្ពោធមួយនៅឯស្រុកឈូក ខេត្តកំពត កាលពីថ្ងៃទី០៩ ខែមេសា លោកបានថ្លែងនៅក្នុងសន្និសីទសារពតិមាន នៅឯសកលវិទ្យាល័យភូមិន្ទកសិកម្មនាក្រុងភ្នំពេញថា ប្រសិនបើអ្នកភូមិទទួលការជួយពីគណបក្សប្រឆាំង ហើយបក្សប្រឆាំងបានធ្វើសកម្មភាពណាមួយនោះ សូមកុំមករកលោកជួយឱ្យសោះ ដែលការតវ៉ារបស់អ្នកភូមិធ្វើឱ្យលោកមិនអាចជួយបានទេ ។

លោកស្រីវេជ្ជបណ្ឌិត **ពុង ឈីវកេក** ប្រធានអង្គការសិទ្ធិមនុស្សលីកាដូមានប្រសាសន៍ថា លោកស្រីធ្លាប់បានឮថា រដ្ឋាភិបាលជារដ្ឋាភិបាលរបស់ប្រជាពលរដ្ឋទូទៅ ។ តាមនិយមន័យលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលប្រសូត្រឡើងដោយប្រជាពលរដ្ឋ រដ្ឋាភិបាលបំរើផលប្រយោជន៍ជូនប្រជាពលរដ្ឋទូទៅ ។ ដូច្នេះរដ្ឋាភិបាលមិនត្រូវមានភាពរើសអើងនោះទេ ។ សព្វថ្ងៃនេះ សង្គមស៊ីវិលប្រជាពលរដ្ឋបានមើលឃើញថា អាជ្ញាធរថ្នាក់មូលដ្ឋានតែងតែប្រកាន់ឬករើសអើងក្រអើត ក្រទមប្រជាពលរដ្ឋណាដែលមាននិន្នាការនយោបាយមិនគាំទ្រគណបក្សកាន់អំណាច។ ស្របពេលដែលប្រមុខរដ្ឋាភិបាលបានបដិសេធមិនជួយប្រជាពលរដ្ឋដែលទៅពឹងពាក់គណបក្សប្រឆាំងផងនោះ ប្រការនេះត្រូវបានគេមើលឃើញថា អាជ្ញាធរមូលដ្ឋានប្រាកដជាបង្កើនភាពរើសអើងបន្ថែមទៀត ។


| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| **លោក** | **ម៉ី សាន** | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| **កញ្ញា** | **គង់ ចន្ធូរ** | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |


**គណបក្សសិទ្ធិមនុស្សប្រកាន់ជំហរខ្មែរមានតែមួយ !**